ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣
## ភាគទាន តាវកាលិក និងប្រាក់បៀវត្សមធ្យមប្រចាំខែ ផ្នែកថែទាំសុខភាព

### ផ្នែកទី ១
### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

អត្រាភាគទានផ្នែកថែទាំសុខភាព បែបបទ និងនីតិវិធីនៃការបង់ភាគទាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

### ផ្នែកទី ២
### តាវកាលិកផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

តាវកាលិកផ្នែកថែទាំសុខភាព ដែលកំណត់ក្នុងអនុក្រឹត្យនេះរួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជំងឺដែលមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងតាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃ ប.ស.ស។

បែបបទ និងនីតិវិធី នៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

យន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**មាត្រា ៩.-**

ការទទួលបានតាវកាលិកថែទាំសុខភាព ត្រូវអនុលោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលធានារ៉ាប់រង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ផ្នែកទី ៣
## ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា ១០.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាព ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ ។

## ជំពូកទី ៤
## ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល
## ផ្នែកទី ១
## ការទទួលស្គាល់គុណភាពសេវា

**មាត្រា ១១.-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាល ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

## ផ្នែកទី ២
## ការត្រួតពិនិត្យគុណភាពសេវា

**មាត្រា ១២.-**

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស។

សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៥
## ដំណាក់កាលនៃការអនុវត្ត

**មាត្រា ១៣.-**

ដំណាក់កាលដំបូង ការផ្តល់សេវាថែទាំសុខភាពត្រូវអនុវត្តចំពោះតែសមាជិក ប.ស.ស និងឧត្តរជីវី។

ការផ្តល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូន ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ត្រូវអនុវត្តជាបន្តបន្ទាប់អនុលោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្តែង ដែលត្រូវកំណត់ដោយប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ